# កិច្ចការផ្ទះ (ពង្រឹងការអាន)

## I.ចូរអានអត្ថបទនិងជ្រើសរើសចម្លើយត្រឹមត្រូវ។



ក្រោយពីនោះ៥ឆ្នាំ ស្ដេចសៀមរកកលល្បិចដើម្បីយកព្រះនាងសក់ក្រអូបឱ្យទាល់តែបាន ក៏ចាត់ការជ្រើសរើសក្រុមល្ខោនភ្លេងដ៏ពិសេស ហើយនឹងជ្រើសយកពពួកមន្ត្រីអ្នករាជការជាច្រើនរូបទៀត ដែលឈ្លាសវៃក្នុងល្បិចស៊ើបការណ៍ផ្សេងៗព្រមទាំងរេពលជាច្រើន បញ្ជូនឱ្យចុះសំពៅសំដៅទៅទិសទក្សិណ ដើម្បីស្វែងរកព្រះនាងសក់ក្រអូប ជាព្រះអគ្គមហេសីស្ដេចបាយ៉ង់កោរម្ដងទៀត។ ពួកមន្ត្រីល្ខោនហើយនឹងពួកពលទាហ៊ានទាំងអស់ គេបានពិភាក្សាគ្នាដឹងកិច្ចការជាស្រេចដោយគេយល់ថាស្ដេចបាយ៉ង់កោរគង់ស្នាក់អាស្រ័យនៅចម្ងាយប្រមាណ១២សិនប៉ុណ្ណោះ។ ត្រង់កោះដែលទីចតសំពៅរបស់ពួកសៀមនោះជាប់ឈ្មោះថា "ជើងប្រជុំ" តមកតែសព្វថ្ងៃគេហៅក្លាយមកជា "ជើងកញ្ជុំ"។ ឯពួកសេនាសៀមកាលបើបានចតសំពៅ បោះយុថ្កាស្រួលបួលហើយគេក៏ដាក់ឈើធ្វើជាស្ពានតពីសំពៅរបស់គេមកភ្ជាប់នឹងកំពង់នៃកោះនោះហើយក៏តាំងរៀបពិធីលេងល្ខោននៅក្នុងសំពៅនោះរាល់ថ្ងៃរាល់យប់។ មនុស្សប្រុសស្រីនៅក្នុងកោះទាំងប៉ុន្មានដោយពុំដែលបានមើលអ្វីឱ្យសប្បាយសោះក៏នាំគ្នាទៅមើលល្ខោននោះយ៉ាងកុះករ ហើយបានទទួលបដិសណ្ឋារកិច្ចយ៉ាងប្រសើរអំពីពួករាជការសៀមទាំងនោះ។ លុះរំលងយូរទៅសេចក្ដីរីករាយរបស់មនុស្សអ្នកកោះនោះ នឹងពួកពលសៀមស្និទ្ធស្នាលគ្នាយ៉ាងប្រពៃ។ ចំណែកពួកសៀមអ្នកខាងស៊ើបការណ៍ ក៏យកការណ៍បានច្បាស់លាស់ ថាស្ដេចបាយ៉ង់កោរពិតជានៅស្នាក់ពួនក្នុងកោះនេះមែន។

LIVEWORKSHEETS

១. តើស្តេចសៀមបានបញ្ជូលពួកពលទាហ៊ានរបស់ខ្លួនទៅទិសខាងណា?

ក. ទិសនីរតី ខ.ទិសទក្សិណ គ.ទិសឧត្តរ

២. តើព្រះនាងសក់ក្រអូបជាអគ្គមហេសី(អគ្គមហេសីមានន័យថាប្រពន្ធ)របស់ស្តេចអង្គណា?

ក. ស្តេចសៀម ខ.ព្រះបាទបាយ៉ង់កោរ

៣. តើស្តេចសៀម(សៀមឈ្មោះក្រៅរបស់ប្រទេសថៃ)តាមរកអ្នកណា?

ក. ប្រជាជនសៀម ខ.ព្រះបាទបាយ៉ង់កោរ គ. ព្រះនាងសក់ក្រអូប

LIVEWORKSHEETS